ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
រដ្ឋបាលជលផល

លេខ: ១៤២៤ ជផ

# សេចក្តីជូនដំណឹង
## ស្តីពី
## រដូវបិទនេសាទ ឆ្នាំ២០១៨

- យោងព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- ប្រកាសលេខ៤៥៨ ប្រក.កសកចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ស្តីពីការកែសម្រួលប្រកាសលេខ ១២៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងដែននេសាទទឹកសាបនិងដែននេសាទសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់សាធារណជន និងអ្នកនេសាទទាំងអស់ឱ្យបានជ្រាបថា រដូវបិទនេសាទសម្រាប់ការនេសាទនៅក្នុងដែននេសាទទឹកសាប ត្រូវបានកំណត់ដូចខាងក្រោម៖

- ចាប់ពីថ្ងៃទី០១ ខែមិថុនា ដល់ថ្ងៃទី៣០ ខែកញ្ញា ចំពោះដែននេសាទទឹកសាបដែលស្ថិតនៅខាងជើងខ្សែស្របទន្លេចតុម្មុខ ដែលរួមមានខេត្តទាំងអស់ជុំវិញបឹងទន្លេសាបនិងបណ្តាខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ រតនគិរី មណ្ឌលគិរី ព្រះវិហារ ប៉ៃលិន ឧត្តរមានជ័យ និងរាជធានីភ្នំពេញ និងខេត្តកណ្តាលផ្នែកខាងជើងចតុម្មុខ។
- ចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែតុលា ចំពោះដែននេសាទទឹកសាបដែលស្ថិតនៅខាងត្បូងខ្សែស្របទន្លេចតុម្មុខ ដែលរួមមាន រាជធានីភ្នំពេញផ្នែកខាងត្បូងចតុម្មុខ ខេត្តកណ្តាល ព្រៃវែង តាកែវ កំពង់ស្ពឺ និងខេត្តស្វាយរៀង។

នៅក្នុងរយៈពេលបិទនេសាទនេះ អ្នកនេសាទទាំងអស់ត្រូវប្រើប្រាស់តែឧបករណ៍នេសាទគ្រួសារដែលមានចែងក្នុងប្រកាសលេខ៤៥៨ ប្រក.កសក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ប៉ុណ្ណោះ។

ចំពោះឧបករណ៍ អួន ម៉ាញ់ ចៃ៉ា ជន សាប នាម ឈ្នក់ មិនអនុញ្ញាតឱ្យប្រើឡើយក្នុងរដូវបិទនេសាទនេះ។ ដោយឡែក ឧបករណ៍នេសាទលបនិងសៃយ៉ឺន អនុញ្ញាតឱ្យប្រើរបាំងព្រលរួមផ្សំមិនលើសពី១០ ម៉ែត្រ ឬមិនលើសពី១/៣នៃទទឹងមុខទឹក រីឯឧបករណ៍មងអាចធ្វើនេសាទបានតែប្រវែង១០០ ម៉ែត្រ ប៉ុណ្ណោះ។

ម្យ៉ាងទៀត សូមបងប្អូនអ្នកនេសាទទាំងអស់អនុវត្តតាមអនុសាសន៍ទាំង៧ ចំណុច របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ឱ្យបានខ្ជាប់ខ្ជួន ជាពិសេសជួយការពារកន្លែងអភិរក្សជលផលឱ្យបានគង់វង្ស ដើម្បីទុករក្សាពូជត្រី។

រដ្ឋបាលជលផលសង្ឃឹមថា សាធារណជន និងអ្នកនេសាទទាំងអស់ នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ដើម្បីចូលរួមចំណែកថែរក្សានិងការពារធនធានជលផលឱ្យបានគង់វង្ស សម្រាប់ប្រជាពលរដ្ឋខ្មែរយើងក្នុងជំនាន់នេះ ក៏ដូចជាជំនាន់ក្រោយៗទៀត។

ថ្ងៃ ៣ ៗ១១ រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១៨
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**

**ចម្លងជូន៖**
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  «ដើម្បីជូនជ្រាបជាព័ត៌មាន»
- គ្រប់រដ្ឋបាលខេត្ត-រាជធានី
  «ដើម្បីជួយជំរុញការអនុវត្តឱ្យមានប្រសិទ្ធិភាព»
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់អង្គភាពក្រោមឱវាទរដ្ឋបាលជលផល
  «ដើម្បីចាត់វិធានការបង្ក្រាបបទល្មើសឱ្យបានតឹងរឹង និងមានប្រសិទ្ធិភាពបំផុត»
- ស្ថានីយ៍វិទ្យុនិងទូរទស្សន៍
  «ដើម្បីជួយធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ»
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានៈអាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ៥៨២ ទូ/Fax: (855) 23 215 470 www.fia.gov.kh